FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ការជ្រើសរើសពូជស្រូវសម្រាប់ដាំដុះ

**ហេតុអ្វីបានជាត្រូវប្រើពូជតម្រូវតាមតំបន់ ?**

ពូជដែលប្រើប្រាស់ទៅតាមតម្រូវការតំបន់ អាចធានាបាននូវការដុះលូតលាស់ល្អ និងទិន្នផលខ្ពស់ ព្រមទាំងគុណភាពត្រូវបានទទួលស្គាល់នៅលើទីផ្សារ ។



**ការគិតគូទៅលើពូជ**

ពូជគួតែ:

- មានគុណភាពល្អ (ជាពិសេសលក្ខណៈសម្បត្តិពេលចម្អិន ដូចជា:ពណ៌ រូបរាង រសជាតិ និងក្លិន ទទួលស្គាល់ពីកសិករភាគច្រើន និងទីផ្សារក្នុងស្រុកឲ្យសមទៅនឹងតម្លៃដែលកសិករចង់បាន
- ទិន្នផលខ្ពស់ និងមានលក្ខណៈបិតថេរនៅរដូវដាំដុះក្រោយៗ
- ធន់ទ្រាំនឹងសត្វល្អិត ជំងឺសាហាវផ្សេងៗ ហើយធន់នឹងបរិយាកាសជុំវិញ ដែលមានការបំរែបំរួលខ្លាំង (ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ជាដើម)
- កំឡុងពេលលូតលាស់ដែលទន្ទឹមទៅនឹងរដូវកាល កុំប្រើពូជណាដែលត្រូវដាំ និងប្រមូលផលឆាប់ ឬយឺត បើធៀបទៅនឹងវាលស្រែផ្សេងៗទៀត នៅក្នុងតំបន់ជុំវិញវា ។ ស្រូវដែលមានរយៈពេលមិនសមស្របអាចបណ្តាលឲ្យ:

  - បង្កើនការខូចខាតដោយសារសត្វ (ដូចជា សត្វស្លាបស៊ីនៅពេលស្រូវទុំ ) ឬ

- បញ្ហាក្នុងការលូតលាស់នៅពេលដែលមានលក្ខខណ្ឌបរិយាកាសជុំវិញអាក្រក់ (ដូចជាគ្រាប់ទុំក្រោយគេ អាចមកពីទទួលទឹកមិនបានគ្រប់គ្រាន់)

- សមត្ថភាពគ្រប់គ្រាន់ក្នុងការដាក់គ្រាប់ ដោយមិនទទួលរងឥទ្ធិពលឬម្លប់ពីស្មៅ ឬរុក្ខជាតិដទៃ និងមានសមត្ថភាពបែកគុម្ពបានគ្រប់គ្រាន់ដើម្បីទទួលបានទិន្នផលសមស្រប

- ធន់ទៅនឹងការដួលរលំ ។

## ការគិតគូរទៅលើការងារគ្រប់គ្រង

- ធានាថាពូជវាមានលក្ខណៈសមស្របទៅនឹងវិធីសាស្ត្រដាំដុះ និងការអនុវត្តន៍ការងារគ្រប់គ្រងរបស់កសិករ (ដូចជាពូជមួយចំនួនគឺសមស្របជាងគេសម្រាប់យកទៅព្រោះ ជាងយកទៅសាបឬ ទៅធ្វើអ្វីផ្សេងទៀត )

- ប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពល្អ (គ្រាប់ពូជដែលមានអត្រាដំណុះ ក្នុងទីពិសោធន៍ និងនៅវាល ស្រែខ្ពស់ជាង៨០ភាគរយ) ដើម្បីទទួលបានទិន្នផលខ្ពស់

- ធានាបានថា មានគ្រាប់ពូជគ្រាប់គ្រាន់ដើម្បីបំពេញតម្រូវការក្នុងស្រុក

-នៅក្នុងតំបន់តែមួយត្រូវផលិតពូជផ្សេងៗគ្នា ព្រោះវាអាចជួយរក្សាជីវចម្រុះ និងភាពធន់របស់ពូជទៅនឹងសត្វចង្រៃ ជំងឺ និងជួយពន្យឺតការរីករាលដាលរបស់សត្វចង្រៃបានផងដែរ ។

## ការវាយតម្លៃទៅលើប្រភេទពូជថ្មី

- ដើម្បីធានាថាពូជមានលក្ខណៈសមស្រប យ៉ាងតិចបំផុតត្រូវធ្វើការសាកល្បងលើសពីពាររដូវនៅក្នុងស្រែកសិករ ។ ពូជសមស្របផ្តល់ទិន្នផលថេរ ហើយធន់ទៅនឹងសត្វចង្រៃក្នុងតំបន់ ព្រមទាំងសមស្របទៅនឹងលក្ខខណ្ឌ ក្នុងតំបន់ផងដែរ

- វាយតម្លៃពូជថ្មីដោយការប្រើប្រាស់ ការគ្រប់គ្រងស្រូវ ដែលវាស្រដៀងគ្នាទៅនឹងការអនុវត្តន៍របស់កសិករ ដូចជាបើកសិករប្រើជីតិច ពេលសាកល្បងត្រូវប្រើជីតិចដែរ បើកសិករព្រោះពេលសាកល្បងត្រូវធ្វើស្រូវពព្រោះ មិនត្រូវធ្វើទៅលើស្រូវសន្ទូងទេ

- ពិគ្រោះជាមួយកសិករ ដើម្បីធានាថាពូជមានលក្ខណៈសមស្របមុនពេលបញ្ចេញវា

- ធានាឲ្យបានថា គុណភាពគ្រាប់ពូជថ្មីនេះមានការទទួលស្គាល់នៅលើទីផ្សារ និងតម្លៃសមរម្យ

-កសិករអាចកាត់បន្ថយភាពប្រថុយប្រថាន ដោយគ្រាន់តែសាកល្បងធ្វើវានៅក្នុងផ្នែកមួយនៃផ្ទៃដីទាំងអស់របស់គាត់បានហើយ ។